# ពិធីបុណ្យកឋិនទាន



*ពិធីបុណ្យកឋិនទាន*

*កឋិនទាន ជាផ្នែកមួយរបស់ចីវរទាន ប៉ុន្តែទាននេះមានលក្ខណៈពិសេសប្លែកពីចីវរទាន ធម្មតា ព្រោះអ្នកធ្វើនិងអ្នកទទួល ត្រូវគោរពឲ្យបានត្រឹមត្រូវតាមលក្ខខ័ណ្ឌមួយចំនួនដែលមានចែងក្នុងព្រះវិន័យ ។*

I - ប្រភពកឋិនទាន

សម័យពុទ្ធកាល ពេលដែលព្រះសម្មាសម្ពុទ្ធទើបបានត្រាស់ដឹងថ្មីៗ ទ្រង់អនុញ្ញាតឲ្យភិក្ខុសង្ឃប្រើប្រាស់តែសំពត់បង្សុកូល គឺសំពត់ឥតម្ចាស់ ដែលភិក្ខុរកបានពីព្រៃស្មសាន ឬពីគំនរសំរាម ប៉ុន្តែក្រោយមកទើបទ្រង់អនុញ្ញាតឲ្យភិក្ខុអាចប្រើប្រាស់គហបតីចីវរ គឺសំពត់មានម្ចាស់ ដែលភិក្ខុបានមកដោយសារគេប្រគេន ។ ចាប់ពីពេលនេះហើយ ដែលកឋិនទានចាប់ផ្តើមមានកំណើតឡើង ។ ឯរឿងរ៉ាវដែលទាក់ទងដល់បញ្ហានេះ មានដំណើរសង្ខេបដូចតទៅ :

សម័យនោះ ព្រះដ៏មានព្រះភាគគង់ក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី ។ គ្រានោះពួកភិក្ខុនៅក្នុងដែនបាឋេយ្យ ប្រមាណ៣០រូប សុទ្ធតែជាអ្នកប្រព្រឹត្តប្រើតែចីវរបី នាំគ្នាទៅកាន់ក្រុងសាវត្ថី ដើម្បីគាល់ព្រះមានព្រះភាគ, កាលបើតិថីចូលវស្សាជិតណាស់មកហើយ ក៏មិនអាចនឹងទៅឲ្យទាន់ចូលវស្សា ក្នុងក្រុងសាវត្ថីបានឡើយ ហើយក៏នាំគ្នាចូលទៅចាំវស្សាក្នុងក្រុងសាកេត នាកណ្តាលផ្លូវ ។ ភិក្ខុទាំងនោះ នៅចាំវស្សាទាំងមានសេចក្តីអផ្សុកយ៉ាងខ្លាំង ព្រោះគិតថា ព្រះមានព្រះភាគគង់នៅក្នុងទីជិតយើងទាំងឡាយ ចម្ងាយ៦យោជន៍អំពីទីនេះ តែយើងទាំងឡាយ មិនសមបើមិនបានទៅគាល់ព្រះអង្គសោះ ។

លុះភិក្ខុទាំងឡាយ នៅចាំវស្សាគ្រប់បីខែហើយ ក៏នាំគ្នាធ្វើបវារណាចេញវស្សា រួចធ្វើដំណើរតម្រង់ទៅកាន់ក្រុងសាវត្ថី ។ ដោយរដូវនោះនៅមានភ្លៀងធ្លាក់ជោកជាំ មានទឹកភក់រអិលនៅឡើយ, ភិក្ខុទាំងនោះក៏មានចីវរទទឹកជោគ មានការលំបាក ប៉ុន្តែតស៊ូធ្វើដំណើររហូតដល់វត្តជេតពន ដែលព្រះមាន ព្រះភាគគង់នៅ ។ ពេលចូលទៅដល់ពួកភិក្ខុទាំងនោះក៏ថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លំដាប់នោះ ព្រះសាស្តាមានព្រះបន្ទូលថា "ម្នាលភិក្ខុទាំងឡាយ អ្នករាល់គ្នាល្មមអត់ទ្រាំបានទេឬ អ្នករាល់គ្នាល្មមប្រព្រឹត្តទៅបានស្រួលទេ ឬអ្នកទាំងឡាយមានសាមគ្គីស្មោះសរ មិនវិវាទទាស់ទែងគ្នា នៅចាំវស្សាស្រួលបួល មិនលំបាកដោយអាហារបិណ្ឌបាតទេឬ? ភិក្ខុទាំងនោះក៏ក្រាបទូលរៀបរាប់អំពីដំណើរដើមដានដែលខកមកចូលវស្សានៅក្នុងក្រុងសាវត្ថីជាមួយព្រះអង្គ និងពីសុខទុក្ខរបស់ខ្លួនក្នុងការនៅចាំវស្សាពាក់កណ្តាលផ្លូវនោះ ព្រមទាំងទូលពីការលំបាកក្នុងការធ្វើដំណើរមកគាល់ព្រះអង្គនៅទីនេះ ។ ព្រះសាស្តាលុះទ្រង់ព្រះសណ្តាប់ហើយ ក៏ទ្រង់ធ្វើធម្មិកថា ត្រាស់ហៅភិក្ខុទាំងឡាយឲ្យមកជួបជុំគ្នា ហើយទ្រង់អនុញ្ញាតថា ***អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ ។ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ អនាមន្តចារោ អសមាទានចារោ គណភោជនំ យាវទត្ថចីវរំ យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ*** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលបាននៅចាំវស្សារួចហើយក្រាលកឋិនបាន ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយបានក្រាលកឋិន (ប្រកាសឲ្យសង្ឃឮគ្រប់រូបថាយកចីវរណា (ស្បង់ចីពរ ឬសង្ឃាដី ជាកឋិន)។ ហើយនិងសម្រេចអានិសង្ស៥យ៉ាងគឺ ត្រាច់ទៅណាមិនបាច់លាភិក្ខុផងគ្នា១ ត្រាច់ទៅណាមិនបាច់

យកត្រៃចីវរ គ្រប់ប្រដាប់១ ឆាន់គណភោជនបាន១ ទុកដាក់អតិរេកចីវរបានតាមត្រូវការ១ ចីវរណាដែលកើតឡើងក្នុងអាវាសនោះ ចីវរនោះនឹងមានដល់ភិក្ខុទាំងនោះ១។

ដោយសារមានពុទ្ធានុញ្ញាតនោះហើយ ទើបពុទ្ធបរិស័ទនាំគ្នាបាត់ចែងសំពត់ឬចីវរយកទៅវេរប្រគេនចំពោះសង្ឃដែលបានគង់ចាំវស្សាម៉ត់ចត់មិនដាច់ ដើម្បីអនុគ្រោះឲ្យព្រះសង្ឃមានចីវរប្រើប្រាស់ផង ដើម្បីឲ្យព្រះសង្ឃបានអានិសង្ស៥ប្រការផង ដើម្បីជាការកុសលផ្ទាល់ខ្លួនផង។

## II - លក្ខខណ្ឌបុណ្យកឋិនទាន

ដោយកឋិនជាទានពិសេសប្លែកពីទាននានា ឬចីវរទានធម្មតានោះអ្នកធ្វើនិងភិក្ខុសង្ឃអ្នកទទួល ត្រូវគោរពដាច់ខាតនិងម៉ឺងម៉ាត់បំផុតតាមលក្ខខណ្ឌដែលមានចែងនៅក្នុងវិនយប្បញ្ញត្តិ ដូចតទៅ :

១-លក្ខខ័ណ្ឌសម្រាប់អ្នកធ្វើ អ្នកណាក៏អាចធ្វើកឋិនទានបានទោះជាមនុស្សក្ដី ទេពតាក្ដី អ្នកបួសក្ដី គ្រហស្ថក្ដី កាលណាដល់កឋិនកាល គឺរដូវកឋិនដែលមានរយៈកាល ២៩ថ្ងៃ ដោយ គិតពីថ្ងៃ១រោច ខែអស្សុជ ដល់១៥កើត ខែកត្តិក ហើយអាចយកសំពត់ដែលល្មមកាត់ដេរធ្វើជាស្បង់ ឬចីពរឬក៏សង្ឃាដីបានទៅវេរចំពោះព្រះភិក្ខុសង្ឃដែលបានគង់ចាំវស្សាអស់ត្រីមាសដោយពាក្យ*ឋា ឥមំ ទុស្សំ កឋិនំ សង្ឃស្ស ទេម* យើងខ្ញុំសូមវេរសំពត់នេះ ចំពោះព្រះសង្ឃដើម្បីក្រាលកឋិន ប៉ុណ្ណោះជាការស្រេច។ ប្រសិនបើ អ្នកចេះកាត់ដេរជ្រលក់ធ្វើជាស្បង់ឬចីពរ ឬសង្ឃាដីឲ្យស្រេច ទើបយកទៅវេរចំពោះភិក្ខុសង្ឃដែលបានគង់ចាំវស្សាគ្រប់ត្រីមាសក្នុងវត្តណាមួយនោះដោយបញ្ចេញវាចាថា *ឥមំ កឋិនចីវរំ សង្ឃស្ស ទេម* យើងខ្ញុំសូមវេរកឋិនចីវរនេះ ចំពោះព្រះសង្ឃ ប៉ុណ្ណោះជាការស្រេចអ្នកនោះឈ្មោះថាបានធ្វើកឋិនហើយ។

២-លក្ខខណ្ឌសម្រាប់ទទួល : ព្រះសង្ឃឬភិក្ខុជាអ្នកទទួលឬជាអ្នកក្រាលកឋិន ត្រូវអនុវត្តឲ្យបានម៉ត់ចត់តាមលក្ខខណ្ឌដែលមានចែងក្នុងវិនយប្បញ្ញត្តិជាអាទិ៍ :

- សង្ឃអាចទទួលកឋិនបានតែក្នុងរដូវកឋិនកាល។
- ភិក្ខុអ្នកបាននៅចាំវស្សាអស់ត្រីមាស។
- សង្ឃអ្នកទទួល ត្រូវមានភិក្ខុចាប់ពី ៥រូបឡើងទៅ។
- បើគេប្រគេនជាដាច់សំពត់សុទ្ធ សង្ឃត្រូវយកទៅធ្វើឲ្យកើតជាស្បង់ឬចីពរឬជាសង្ឃាដីត្រឹមត្រូវទើបយកទៅក្រាល។
- ត្រូវធ្វើពិធីក្រាលកឋិនឲ្យចប់ក្នុងថ្ងៃដែលគេវេរប្រគេន គឺមិនត្រូវបង្អង់ពេល ឬពន្យារពេលឲ្យកន្លងរាត្រីបានឡើយ។
- ភិក្ខុក្រាលត្រូវចេះអានិសង្ស៥ មាតិកា ៨ បលោពោធ ២ អនត្ថតាការៈ ២៤ អត្ថតាការៈ ១៧។
- ភិក្ខុអ្នកក្រាមានសិទ្ធយកតែស្បង់១ ឬចីពរ១ ឬសង្ឃាដី១ ប៉ុណ្ណោះលាភ ឬជាបរិក្ខារបន្ទាប់បន្សំរបស់កឋិន។

## III - កឋិនទាននៅកម្ពុជា

កិនទានក្នុងជំនាន់ពុទ្ធកាល ហាក់ដូចជាងាយនឹងធ្វើសោះ ទោះបីជនក្រីក្រ ខ្វះខាត ថ្នាក់ទាបបំផុតក៏ដោយ ឲ្យទេមានស្បង់១ ឬចីពរ១ ឬសង្ឃាដី១ឬមានសំពត់ត្រឹមតែពីរឬបីម៉ែត្រ ក៏អាចយកទៅវេរចំពោះ ព្រះសង្ឃដែលគង់ចាំវស្សាអស់ត្រីមាសក្នុងវត្តណាមួយ ក៏ឈ្មោះថាជាអ្នកបានធ្វើកឋិនហើយ ប៉ុន្តែបុណ្យកឋិនទាននៅកម្ពុជា លុះណាតែអ្នកមានស្តុកស្តម្ភឬគ្នាច្រើនទើបអាចធ្វើកឋិនកើតព្រោះកឋិនទាននៅកម្ពុជា ពុំមែនមានត្រឹមតែស្បង់១ចីពរ១ ឬសង្ឃាដី១ប៉ុណ្ណោះទេ គឺត្រូវ

មានបរិក្ខារដ៏ច្រើនផ្សេងៗទៀតជាពិសេស បច្ច័យសង្កត់ត្រៃសម្រាប់កសាងវត្តអារាមនិងសមិទ្ធិសាធារណៈ មានសាលារៀន មន្ទីរពេទ្យ ជាដើម។

*១-គម្រោងបុណ្យកឋិនទាន*

កាលណាថ្ងៃបវារណាចេញវស្សារបស់ព្រះសង្ឃជិតមកដល់ ពុទ្ធបរិស័ទគ្រប់ជើងវត្តនានាក្នុងប្រទេសកម្ពុជាទាំងមូល តែងតែពិភាក្សាគ្នាដើម្បីធ្វើកឋិនទានប្រគេនព្រះសង្ឃគ្រប់វត្តអារាមតាមស្ម័គ្ររៀងខ្លួនដោយមានជំនឿជាប់មកជាទំនៀមថា កឋិនទាន ជាកាលទាន មានផលានិសង្សច្រើនជាងទានទាំងពួង គឺអ្នកធ្វើក៏បានអានិសង្ស អ្នកទទួលក៏បានអានិសង្ស។ ជំនឿនេះបានចាក់ឫសជាប់នៅក្នុងចិតថ្លើមរបស់ពុទ្ធសាសនិកជនទូទាំងប្រទេស រហូតដល់សំគាល់វត្តដែលដល់រដូវកឋិនហើយ គ្មាននរណាហែកឋិនចូលជាវត្តមិនស្មើមុខនិងវត្តដែលមាន។ ដូច្នេះហើយបានជាវត្តណា ដែលគ្មានពុទ្ធបរិស័ទក្រៅជើងវត្តហែកឋិនចូល ពុទ្ធបរិស័ទជាចំណុះជើងវត្តនោះ តែងស្មុះស្មា អង្គាសគ្នាធ្វើទាល់តែកើតជាអង្គកឋិនទានឡើងមិនទុកឲ្យទំនេរឡើយ។ បុណ្យកឋិននេះ មិនមែនត្រឹមតែជាទំនៀមទម្លាប់របស់ប្រជារាស្ត្រប៉ុណ្ណោះទេ សូម្បីតែព្រះរាជា ព្រះរាជរដ្ឋាភិបាលកម្ពុជា ក៏តែងតែទ្រង់ធ្វើនិងចូលរួមពុំដែលអាក់ខានឆ្នាំណាឡើយ។

អ្នកមានធនធានច្រើន ដែលមានបំណងនឹងធ្វើកឋិនដង្ហែទៅវេរប្រគេនព្រះសង្ឃក្នុងវត្តណាមួយ តែងតែសុំ ឬឲ្យដំណឹងទៅព្រះសង្ឃ ឬអាចារ្យវត្តនោះដឹងជាមុន ជាពិសេសតាំងពីក្នុងវស្សាម្ល៉េះ ថាខ្លួនហែកឋិនទានមកកាន់វត្តនោះនៅថ្ងៃនេះ ឬថ្ងៃនោះពុំខាន។ ឯពុទ្ធបរិស័ទ ចំណុះជើងវត្តនីមួយៗ ក៏តែងតែទន្ទឹងរង់ចាំដំណឹងតាំងពីក្នុងវស្សាដែរ ថាតើវត្តរបស់ខ្លួនមានភ័ព្វវាសនា និងបានទទួលកឋិនទានរបស់លោកអ្នកណា? កឋិនទាននោះឱឡារិក ធំដុំ ឬក៏តូចតាមល្មមទេ?

*២-រណ្តាប់កឋិនទាន :*

បន្ទាប់ពីបានសម្រេចថា និងរៀបចំធ្វើជាអង្គកឋិនហើយ អ្នកសាមីដើមទានតែងតែខ្វល់ខ្វាយពឹងពាក់លោកអាចារ្យ ឬព្រឹទ្ធាចារ្យដែលធ្លាប់យល់ដឹង ឬធ្លាប់មានពិសោធន៍ ក្នុងការរៀបគ្រឿងរណ្តាប់កឋិន ឲ្យជួយចាត់ចែងរៀបចំឲ្យបានត្រឹមត្រូវតាមទម្លាប់ និងក្រឹត្យក្រមព្រះវិន័យ ។

*ទំនៀមរបស់ប្រជារាស្ត្រកម្ពុជា*

*ក្នុងការរៀបរណ្តាប់អង្គកឋិនទានមានដូចខាងក្រោម*

- រណ្តាប់អង្គកឋិន១សម្រាប់ សម្រាប់ប្រគេនព្រះថេរៈ១អង្គដែលក្រាលគ្រងគឺ ស្បង់១ ចីពរ១, សង្ឃាដី១, អង្ស័ក១, វត្ថពន្ធចង្កេះ១, វត្ថពន្ធទ្រូង១, និសីទនៈ១, ឆត្រ១, បាត១, កំសៀវទឹក១, កន្ទេល១, ខ្នើយ១, មុង១, ភួយ១, គ្រែ១, ឆ្នាំង១, បានស្លាបព្រា....។
- រណ្តាប់ញត្តិ ឬរណ្តាប់សូត្រឆ្វេង-ស្តាំ ២សម្រាប់ : សំរាប់ប្រគេនព្រះថេរៈ២អង្គ ដែលសូត្រញត្តិគឺមានចីវរ១, លៀង, (ស្បង់១, ចីពរ១) និងបរិក្ខារមួយចំនួនទៀត....។
- រណ្តាប់បរិក្ខារច្រើនសម្រាប់ សម្រាប់ប្រគេនព្រះភិក្ខុសង្ឃបរិស័ទ ដែលគង់ហត្ថបាសអនុមោទនាកឋិន។ រណ្តាប់នេះ គេនិយមរៀបធ្វើជាកញ្ចប់ ហើយក្នុងកញ្ចប់នេះមានជាអាទិ៍ ស្បង់ឬសាដក១ទៀនធូប តែ ស្ករ បារី ឈើគូសប្រាសថ្នាំដុសធ្មេញ ថ្នាំពេទ្យ សាប៊ូ សៀវភៅ ប៊ិច ខ្មៅដៃ (ប្រាក់)។ រណ្តាប់នេះ គេអាចធ្វើឲ្យមានចំនួនច្រើនសម្រាប់ប្រគេនសាមណេរផង ប្រសិនបើវត្តនោះមានសាមណេរ។ ក្រៅពីរណ្តាប់ទាំងបីផ្នែកនេះ អ្នកសាមីដើមទាន តែងប្រកាសបវារណានូវប្រាក់មួយចំនួនសម្រាប់ប្រគេនព្រះសង្ឃផ្ទាល់ និងមួយចំនួនធំសម្រាប់កសាងសមិទ្ធិផ្សេងៗ ដូចជា កុដិ វិហារ ស្រះ ខ្លោងទ្វារ របងវត្ត សាលារៀន មន្ទីរពេទ្យ...។ បណ្តាបរិក្ខារទាំងអស់នៃ

កឋិនទាន និយាយសរុបមានតែពីរយ៉ាងគឺស្បង់១ឬចីពរ១, ឬសង្ឃាដី១, ប៉ុណ្ណោះជាកឋិនចីវរ គឺចីវរដែលភិក្ខុត្រូវក្រាលនិងបរិក្ខារក្រៅពីនេះហៅថា អានិសង្សលាភ។

### *៣-កម្មវិធីកឋិន*

បណ្ដា២៩ថ្ងៃ គឺពីថ្ងៃ១រោច ខែអស្សុជ ដល់ថ្ងៃ១៥កើត ខែកត្តិក បើអ្នកសាមីដើមទានស្ម័គ្រថ្ងៃណាមួយហើយ គេតែងបោះជាកម្មវិធីផ្សព្វផ្សាយចែកចាយដល់ញាតិ មិត្ត ជិតឆ្ងាយដើម្បីឲ្យចូលរួមក្នុងពិធីបុណ្យកឋិនរបស់គេ។ សម័យបច្ចុប្បន្ន គេចូលចិត្តកំណត់កម្មវិធីនេះឲ្យត្រូវលើថ្ងៃសៅរ៍និងថ្ងៃអាទិត្យ គឺសូត្រមន្តថ្ងៃសៅរ៍ ដង្ហែទៅអាទិត្យ។

ក/ ថ្ងៃសូត្រមន្ត : ថ្ងៃសូត្រជាថ្ងៃទី១ នៃពិធីបុណ្យកឋិនទាន ដែលគេនិយមធ្វើនៅវេលាល្ងាច។ ល្ងាចនោះនៅគេហដ្ឋានអ្នកសាមីដើមកឋិនទាន គេសង្កេតឃើញមាន :

- ពិធីទទួលបដិសណ្ឋារៈយ៉ាងអធិកអធមដោយភោជនាហារយ៉ាងពោរពាស ចំពោះភ្ញៀវជិតឆ្ងាយ ដែលអញ្ជើញមកចូលបច្ច័យចាប់កុសលជាមួយ។
- ពិធីចម្រើនព្រះបរិត្ត និងសំដែងធម៌ទេសនា។
- ជួនកាលមានសំដែងសិល្បៈ ជូនភ្ញៀវកម្សាន្តផង។
- នៅក្នុងវត្តដែលទទួលអង្គកឋិនទាន ក៏មានពិធីសូត្រមន្តទេសនាដែរ,

ខ/ ថ្ងៃដង្ហែ ឬថ្ងៃថត : ជាថ្ងៃទី២នៃកឋិនទាន ដែលគេនិយមធ្វើនៅពេលព្រឹក។ ព្រឹកនេះ គេសង្កេតឃើញ :

- ការជបជុំគ្នានៅផ្ទះអ្នកសាមីដើមទាន ដើម្បីរថយន្តចូលរួមដង្ហែអង្គកឋិនទានឆ្ពោះទៅកាន់វត្តដែលបានគ្រោងទុក។
- ពេលដង្ហែ គេសង្កេតឃើញនៅជាប់និងមុខរថយន្ត នៃអង្គកឋិនមានចងបដាអក្សរធំៗថា "កឋិនទានដង្ហែទៅកាន់វត្ត......."។
- នៅលើរថយន្ត មានក្រុមឆៃយ៉ាំ ឡកលេងប្រគំកំដរ លាន់ឮរំពងរហូតដល់វត្ត។
- នៅឯវត្តអារាមវិញ គេបានរៀបចំបោសប្រាសយ៉ាងស្អាតតុបតែងលំអដោយទង់ផ្កាលា ទង់ជាតិ ទង់សាសនា រំយោលផ្កាភ្ញីយ៉ាងល្អល្អះព្រោងព្រាត។
- បន្ទាប់ពីប្រគេនភត្តាហារ និងពិធីទទួលអង្គកឋិន និងជូនភោជនាហារចំពោះភ្ញៀវមកមានពិធីដង្ហែអង្គកឋិនប្រទក្សិណព្រះវិហារជាទក្ខិណាព័ត៌ (បត់ពីឆ្វេងទៅស្ដាំ) ដោយមានក្រុមឆៃយ៉ាំប្រគំឡកលេងរាំលេងរាំយោងមុខយ៉ាងក្រមិចក្រមើមគួរសប្បាយរីករាយជ្រះថ្លា, បន្ទាប់មក មានលោកអាចារ្យនាំមុខអ្នកដើមទានទូលត្រៃធំ រណ្ដាប់សូត្រឆ្វេង-ស្ដាំ និងកាន់រណ្ដាប់បរិក្ខារផ្សេងៗ រួចហើយចូលទៅតម្កល់ក្នុងកណ្ដាលព្រះវិហារ ចំពោះព្រះភក្ត្រព្រះពុទ្ធបដិមា និងព្រះភិក្ខុសង្ឃ។ ពេលនោះ មានពិធីនមស្សការព្រះរតនត្រ័យ សមាទានសីល ប្រកាសបច្ច័យសង្កត់ត្រៃវេរអង្គកឋិនចំពោះព្រះសង្ឃ ពិធីក្រាលកឋិន ព្រះសង្ឃសូត្រធម៌អនុមោទនាឲ្យពរសាធុការដល់សាមីដើមទាន និងសប្បុរសជនទាំងអស់។

### *៤-វិធីវេរអង្គកឋិន*

តាមទម្លាប់របស់លោកអាចារ្យដែលជាអ្នកតំណាងម្ចាស់កឋិន តែងវេរអង្គកឋិនចំពោះព្រះសង្ឃតាមវិធីពីរយ៉ាងស្រេចហើយលើការចូលចិត្តរបស់ខ្លួន :

- ពិធីវេរបែបទី១,

- បើគេយកសាច់សំពត់សុទ្ធមកវេរចំពោះព្រះសង្ឃ ដើម្បីក្រាលកឋិននោះ លោកអាចារ្យតែងវេរ*ថា នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស* (បីចប់)។ *ឥមំ ទុស្សំ កឋិនំ សង្ឃស្ស ទេម, ទុតិយម្បិ ឥមំ.... ទេម, តតិយម្បិ ឥមំ...ទេម* យើងខ្ញុំទាំងឡាយ សូមវេរនូវសំពត់នេះដើម្បីកឋិនចំពោះព្រះសង្ឃ, អស់វារៈពីរដងផង អស់វារៈបីដងផង។
- បើគេយកចីវរធ្វើស្រេចមកវេរចំពោះព្រះសង្ឃ ដើម្បីក្រាលកឋិននោះលោកអាចារ្យតែងវេរថា *នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស* (បីចប់) *ឥមំ កឋិនចីវរំ សង្ឃស្ស ទេម, ទុតិយម្បិ ឥមំ...ទេម, តតិយម្បិ ឥមំ...ទេម* យើងខ្ញុំទាំងឡាយ សូមវេរនូវកឋិនចីវរនេះចំពោះព្រះសង្ឃ អស់វារៈពីរដងផង អស់វារៈបីដងផង។
- ប្រសិនបើមានបរិក្ខារផ្សេងៗ ក្រៅពីសំពត់កឋិន ឬកឋិនចីវរផងដែលហៅថាអានិសង្សលាភ នោះលោកអាចារ្យតែងវេរបន្ថែមទៀតថា *យេនម្ហាកំ កឋិនំ គហិតំ កឋិនានិសំសានិតស្សេវ ទេម, ទុតិយម្បិ យេនម្ហាកំ...ទេម, តតិយម្បិ យេនម្ហាកំ... ទេម* រីកឋិននៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណាទទួលកាន់យក យើងខ្ញុំទាំងឡាយសូមវេរនូវបរិក្ខារទាំងឡាយជាអានិសង្សលាភ នៃកឋិនចំពោះលោកម្ចាស់អង្គនោះឯង។ អស់វារៈពីរដងផង។ អស់វារបីដងផង។

- វិធីវេរបែបទី២
  - សម័យបច្ចុប្បន្ន លោកអាចារ្យគ្រប់វត្តនិយមវេរស្ទើរតែទូទៅថា *នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស* (បីចប់)។ *មយំ ភន្តេ ឥមំ កឋិនចីវរំ សានិសំសំ សង្ឃស្ស ទេម កឋិនំ អត្ថរិតុំ សាធុ ភន្តេ សង្ឃោ ឥមំ កឋិនចីវរំ សានិសំសំ សង្ឃស្ស ទេម កឋិនំ អត្ថរិតុំ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ, ទុតិយម្បិ មយំ ភន្តេ...ហិតាយ សុខាយ, តតិយម្បិ មយំ ភន្តេ.... ហិតាយ សុខាយ* បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយសូមវេរនូវកឋិនចីវរព្រមទាំងអានិសង្សលាភនេះចំពោះព្រះសង្ឃដើម្បីក្រាលកឋិន, បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលនូវកឋិនចីវរ ព្រមទាំងអានិសង្សលាភនេះ ដើម្បីក្រាលកឋិន, ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់លោកអ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើម អស់កាលជាយូរអង្វែងទៅហោង អស់វារៈពីរដងផង អស់វារៈបីដងផង។

*៥-ពិធីក្រាលកឋិន*

បំណែកព្រះសង្ឃ កាលបើបានទទួលកឋិនចីវរនោះដោយពិនិត្យពិច័យឃើញថាត្រឹមត្រូវតាមវិន័យសព្វគ្រប់ហើយ ក៏អបលោកឲ្យភិក្ខុ១រូប ដែលជំនុំសង្ឃយល់ថាគួរក្រាលកឋិនបាន, រួចចាត់ភិក្ខុ២រូបសូត្រញត្តិជាភាសាបាលីប្រគល់ចីវរនោះ ដែលមានលំដាប់លំដោយដូចតទៅ :

- "ដំបូងភិក្ខុ១រូបដែលហៅថា "សូត្រឆ្វេង" ចាប់ផ្តើមក្រើនកឋិនដោយ ពាក្យថា "ភន្តេបពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន រីអង្គកឋិនទាននេះ ជារបស់លោក (....) និង (...) សុទ្ធសឹងជាពុទ្ធមាមកជនប្រកបដោយបសាទសទ្ធា និងកុសលចេតនា ជាអសង្ខារិក ជ្រះថ្លាចំពោះគុណព្រះរតនត្រ័យ បានបំពេញនូវបុញ្ញកិរិយាវត្ថុបេះលៃលកយកធនធានដែលគ្មានខ្លឹមសារ ធ្វើឲ្យជារបស់មានខ្លឹមសារកប់ទុកក្នុងព្រះពុទ្ធសាសនា ដើម្បីជាទ្រព្យមត៌កសម្រាប់ប្រើប្រាស់ទៅក្នុងភពខាងមុខទៀត បានស្រុះស្រួលបបួលផ្តួចផ្តើមបង្កើតជាអង្គកឋិនទាននេះឡើង ដើម្បីយកមកវេរថ្វាយភិក្ខុសង្ឃដែលគង់ចាំវស្សាអស់ត្រីមាសក្នុងទីវត្ត (...) នេះ។ ដូច្នេះសំពត់កឋិននេះហាក់ដូចជាសំពត់ទិព្វកោសេយ្យពស្ត្រ អណ្តែតត្រសែតព្ធដ៏អាកាសវេហាស៍នភាល័យ ហើយធ្លាក់ចុះមកក្នុងកណ្តាលជំនុំសង្ឃ ជាសង្ឃទានដ៏ស្មោះឥតចំពោះព្រះករុណាអង្គណាមួយឡើយ។ ហេតុនេះហើយ បើព្រះករុណាអង្គណាមានត្រៃចីវរ

ទុព្វលភាពដាច់ដាចមិនអាចប្រើប្រាស់បាន ហើយចេះនូវអានិសង្ស៥ ចាំមាតិកា ៨ បលិពោធ ២ អនត្ថតាការៈ ២៤ អត្ថតាការៈ ១៧ អាចញ៉ាំងសង្ឃឲ្យគ្រេកអរដោយកឋិនត្ថារកិច្ចបាន ក៏សូមមានព្រះពុទ្ធដីកាឆ្លើយមកចុះ ព្រះសង្ឃនឹងអបលោកសំពត់កឋិននេះ ដល់ព្រះករុណាអង្គនោះដោយញត្តិទុតិយកម្មវាចាក្រាលគ្រងតទៅ។ (ពេលដែលភិក្ខុរូបនេះ ប្រកាសចប់ ត្រូវឈប់បង្អង់២ ឬ៣ នាទីដើម្បីរង់ចាំមើលក្រែងមានភិក្ខុរូបណាដែលមានចីវរដាច់ដាច ឆ្លើយថាខ្លួនចង់ក្រាលកឋិននេះ)។

- បើគ្មានភិក្ខុរូបណាមួយ ឆ្លើយថាខ្លួនសុំក្រាលកឋិននេះទេ ភិក្ខុ១រូបទៀតដែលហៅថា "សូត្រស្តាំ" ត្រូវប្រកាសក្រើនកឋិនដោយពាក្យថា "ភន្តេបពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាជាអ្នកតំណាងសង្ឃគ្រប់អង្គក្នុងឱកាសនេះ សូមពិតព្រះពុទ្ធដីកាចំពោះព្រះសង្ឃគ្រប់អង្គ សូមទានជ្រាប។ យើងខ្ញុំទាំងអស់សុទ្ធសឹងតែមានចីវរល្អមគ្រប់គ្រាន់ប្រើប្រាស់ហើយ ប៉ុន្តែតាមយោបល់របស់ខ្ញុំព្រះករុណាយល់ឃើញថា មានតែព្រះតេជគុណ (...) អង្គនេះ ទើបសមគួរនឹងក្រាលគ្រងនូវសំពត់កឋិននេះ ព្រោះលោកជាអ្នកចេះនូវអានិសង្ស៥ ចាំនូវមាតិកា៨ បលិពោធ២ អនត្ថតាការៈ២៤ អត្ថតាការៈ១៧ ហើយឆ្លៀវឆ្លាសក្នុងកឋិនត្ថារកិច្ចអាចញ៉ាំងសង្ឃឲ្យត្រេកអរបាន។ ហេតុនេះ បើព្រះសង្ឃគ្រប់អង្គយល់ឃើញថាសមគួរដូចជាបកាសនវាចា ដែលខ្ញុំព្រះករុណាបានថ្លែងមកនេះ ក៏សូមបញ្ចេញនូវសញ្ញាថា សាធុ ឲ្យព្រមៗគ្រប់អង្គទៅហោង។ (ពេលនោះ ជំនុំសង្ឃក៏ទទួលព្រមៗគ្នាថា "សាធុ" ។

-បន្ទាប់មក លោកអ្នកសូត្រទាំងពីររូប អង្គុយប្រហោងទឹមគ្នាលើកដៃប្រណម្យឆ្ពោះទៅរកភិក្ខុដែលត្រូវក្រាលគ្រង ដោយសូត្របាលី ញត្តិទុតិយកម្មវាចា ថា សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ យទិសង្ឃស្ស បត្តកល្លំ សង្ឃោ ឥទំ កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ សង្ឃោ ឥទំ កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ ។ យស្សាយស្មតោ ខមតិ ឥមស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ កឋិនំ អត្ថរិតុំ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតសំពត់កឋិននេះកើតឡើងដល់សង្ឃហើយ។ បើកម្មមានកាលគួរដល់សង្ឃហើយ គួរសង្ឃឲ្យសំពត់កឋិននេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីនឹងក្រាលកឋិន។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតសំពត់កឋិននេះកើតឡើងដល់សង្ឃហើយ។ ឥឡូវសង្ឃឲ្យសំពត់កឋិននេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីនឹងក្រាលកឋិន។ ការឲ្យសំពត់កឋិននេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីនឹងក្រាលកឋិនបើគួរដល់លោកមានអាយុអង្គណា ត្រូវលោកមានអាយុអង្គនោះស្ងៀម បើមិនគួរដល់លោកមានអាយុអង្គណាទេ ត្រូវលោកមានអាយុអង្គនោះនិយាយឡើង។ សំពត់កឋិននេះ សង្ឃឲ្យដល់ភិក្ខុឈ្មោះនេះ ដើម្បីនិងក្រាលកឋិនហើយ។ ការឲ្យសំពត់កឋិននេះគួរដល់សង្ឃហើយ ព្រោះហេតុនេះបានជាសង្ឃស្ងៀម។ ខ្ញុំសូមចាំទុកនូវការនេះដោយអាការៈស្ងៀមនៅយ៉ាងនេះ។

-ភិក្ខុអ្នកក្រាល ត្រូវសូត្របាលីដកសង្ឃាដី ចីពរ ស្បង់ចាស់ចេញថា ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ អាត្មាអញដកនូវសង្ឃាដីនេះ។ ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ អាត្មាអញដកនូវចីពរនេះ។ ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ អាត្មាអញដកនូវស្បង់នេះ។

-ភិក្ខុអ្នកក្រាលត្រូវយកខ្មៅដៃធ្វើពិន្ទុកប្បត្រង់មុមចីវរ ដែលបម្រុងក្រាល (គឺធ្វើជាចំណុចមួយមូលដូចជារាងកូនឃ្លី) បើយកស្បង់ថា ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។ ទុតិយម្បិ... តតិយម្បិ... អាត្មាអញអធិដ្ឋាននូវស្បង់នេះ អស់វារៈពីរដងផង, អស់វារៈបីដងផង។ បើចីពរថា ឥមំ ឧត្តរាសង្គំ អធិដ្ឋាននូវចីពរនេះ អស់វារៈពីរដងផង, អស់វារៈបីដងផង។ បើសង្ឃាដីថា ឥមំ សង្ឃាដឹ អធិដ្ឋាមិ..., ទុតិយម្បិ... តតិយម្បិ... អាត្មាអញអធិដ្ឋាននូវសង្ឃាដីនេះ អស់វារៈពីរដងផង, អស់វារៈបីដងផង។

ភិក្ខុអ្នកក្រាល ត្រូវដោះសង្ឃាដីចាស់ ចីពរចាស់ ស្បង់ចាស់ណាមួយដែលខ្លួនត្រូវក្រាលគ្រងចេញ ហើយទ្រង់ស្បង់ថ្មី ចីពរថ្មី សង្ឃាដីថ្មី រួចគង់បត់ព្រះបាទលើកព្រះហស្តសំពះជំនុំសង្ឃ១ សំពះតបវិញ បើយកសង្ឃាដីក្រាលត្រូវប្រកាសប្រាប់ជំនុំ

សង្ឃឋា ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ ខ្ញុំក្រាលកឋិនដោយសង្ឃាដីនេះ។ បើយកចីពរក្រាលត្រូវប្រកាសប្រាប់ជំនុំសង្ឃឋា ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ ខ្ញុំក្រាលកឋិនដោយចីពរនេះ។ បើយកស្បង់ក្រាលត្រូវប្រកាសប្រាប់ជំនុំសង្ឃឋា ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ ខ្ញុំក្រាលកឋិនដោយស្បង់នេះ។

-ភិក្ខុអ្នកក្រាលត្រូវអង្គុយប្រហោងប្រណម្យអញ្ជលីឆ្ពោះទៅរកសង្ឃឬគណៈ ឬបុគ្គល (ដែលបាន គង់ចាំវស្សាជាមួយគ្នា) ហើយពោលថា អត្ថតំ អាវុសោ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទថ (អនុមោទាហិ) ម្នាលអាវុសោ កឋិនរបស់សង្ឃ ខ្ញុំក្រាលហើយ ការក្រាលកឋិន (នេះ) ប្រកបដោយធម៌ សូមលោកទាំងឡាយអនុមោទនាចុះ។

- ភិក្ខុអ្នកអនុមោទនា ត្រូវអង្គុយប្រហោងប្រណម្យអញ្ជលីពោលថា *អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាម* បពិត្រលោកម្ចាស់ដ៏ចម្រើន កឋិនរបស់សង្ឃ លោកក្រាលរួចហើយ, ការក្រាលកឋិន (នេះ) ប្រកបដោយធម៌ យើងសូមអនុមោទនា"។

លុះចប់ពិធីក្រាលនេះហើយ ព្រះសង្ឃក៏សូត្រធម៌ប្រសិទ្ធិពរជូនសាមីដើមទាន និងសប្បុរសជនទាំងអស់។ លោកអាចារ្យ ក៏នាំសូត្រធម៌ យំ កិញ្ចិ... ឧទ្ទិសកុសលជូនចំពោះបុព្វការីជន ដែលបានធ្វើមរណកាលទៅហើយ ជាកិច្ចបញ្ចប់ពិធីបុណ្យកឋិនទានរបស់ខ្លួន ក្នុងបរិយាកាសសប្បាយរីករាយ និងមនោសញ្ចេតនាជ្រះថ្លាឥតឧបមា។

## I V-សេចក្តីសន្និដ្ឋាន

កឋិនជាពិធីជូនរង្វាន់ ឬផ្តល់សិទ្ធិពិសេស លើកទឹកចិត្តចំពោះភិក្ខុសង្ឃ ដែលបានខិតខំយកចិត្តទុកដាក់រៀនសូត្រប្រតិបត្តិធម៌វិន័យ ទ្រាំទ្រការលំបាកផ្សេងៗ អស់ថេរវេលាបីខែក្នុងរដូវវស្សា។ ភិក្ខុសង្ឃដែលបានសម្រេចទិសដៅគ្រប់ផែនការ នៃការចាំវស្សា អាចមានសិទ្ធិក្រាលកឋិន និងអនុមោទនាកឋិនបាន។ កាលបើបានទទួលកឋិនហើយ និងបានអានិសង្ស គឺសិទ្ធិ ឬផលប្រយោជន៍៥ យ៉ាងអស់រយៈកាល៥ខែ គឺពីថ្ងៃទទួលកឋិន រហូតដល់ថ្ងៃ១៥កើត ខែផល្គុន។ ដោយឡែកកឋិនទាននេះ ពុំមែនជាចលនាសកម្មស្ថិតនៅតែក្នុងក្របខ័ណ្ឌ និងបម្រើតែផលប្រយោជន៍ខាងផ្នែកពុទ្ធសាសនាប៉ុណ្ណោះទេ តាមពិត កឋិនទានបានក្លាយជាចលនាសកម្មរបស់សង្គមកម្ពុជាទាំងមូលនិងបម្រើសំណូមពរជំរុញជាក់ស្តែងរបស់ប្រជារាស្ត្រកម្ពុជាទាំងប្រទេសចូលជ្រៅក្នុងកិច្ចកសាង និងអភិវឌ្ឍន៍ប្រទេសជាតិតាំងពីបុរាណកាល រហូតមកដល់បច្ចុប្បន្នកាលនេះ។

រៀបរៀងដោយ

ម៉ែន-ប្រាជ្ញ និង អាំ ធន

ពិនិត្យសម្រួលដោយ ឱម ខែម